ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តតាកែវ**

-សំណុំរឿងព្រហ្មទណ្ឌលេខ: ៩៥៧
ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២៣
-សាលក្រមព្រហ្មទណ្ឌលេខ: ១៧ "ញ"
ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៤

# សាលក្រម

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តតាកែវ

បានបើកសវនាការជាសាធារណៈនៅសាលាដំបូងខេត្តតាកែវ នាថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៤ វេលាម៉ោង ៤ និង ៣០នាទីរសៀល ដោយមានសមាសភាពចូលរួមដូចតទៅ:

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

លោកស្រី [redacted] ចៅក្រម នៃសាលាដំបូងខេត្តតាកែវ

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ចៅក្រម នៃសាលាដំបូងខេត្តតាកែវ

លោកស្រី [redacted] ចៅក្រម នៃសាលាដំបូងខេត្តតាកែវ

**តំណាងអយ្យការ**

លោកស្រី [redacted] ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងខេត្តតាកែវ

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជី នៃសាលាដំបូងខេត្តតាកែវ

**ដើម្បីជំនុំជម្រះ**

លើសំណុំរឿងព្រហ្មទណ្ឌលេខ៖ ៩៥៧ ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២៣ ដែលមានជនជាប់ចោទ៖

១-ឈ្មោះ [redacted] **វុធ ហៅ តុង** ភេទប្រុស អាយុ៣២ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរជាងផ្សារដែក មានទីកន្លែងកំណើត និងទីលំនៅមុនពេលឃាត់ខ្លួននៅភូ[redacted] ខេត្តតាកែវ ឪពុកឈ្មោះ [redacted] **លុច** (រស់) ម្ដាយឈ្មោះ [redacted] **ហាក់** (រស់) មានប្រពន្ធឈ្មោះ [redacted] **ស្រីយ៉ាស** (រស់) មានកូន ០១នាក់ ជានីតិជន កម្រិតវប្បធម៌រៀនថ្នាក់ទី០៤ ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ៖ ធ្លាប់ជាប់ពន្ធនាគារខេត្តតាកែវក្នុងឆ្នាំ២០១៨ រយៈពេល ០២ឆ្នាំ និង ០៦ខែ ករណីគ្រឿងញៀន ។ (ឃុំខ្លួនថ្ងៃទី១៥-០៩-២០២៣)

ជាប់ចោទពីបទ៖ **ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិមឿងចារ ឃុំជាងទង និងភូមិណងស្រាយ ឃុំតាភេម ស្រុកត្រាំកក់ ខេត្តតាកែវ កាលពីថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២៣ បទល្មើសដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។



Scanned with CamScanner

២-ឈ្មោះ [redacted] គា ភេទប្រុស អាយុ៣៥ឆ្នាំ (កើតថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ១៩៨៨) ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរមិនពិតប្រាកដ មានទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ននៅភូមិ[redacted] ខេត្តតាកែវ ឪពុកឈ្មោះ [redacted] ហួត (រស់) ម្តាយឈ្មោះ [redacted] សុខុម (រស់) មានប្រពន្ធឈ្មោះ **ភក្រា** (រស់) ជានីតិជន។ (គេចខ្លួន)

ជាប់ចោទពីបទ៖ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិបឿងចារ ឃុំជាងទង និងភូមិណែងស្រាយ ឃុំតាភេម ស្រុកត្រាំកក់ ខេត្តតាកែវ កាលពីថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២៣ បទល្មើសដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

ដោយមានលោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ។

-បានឃើញ របាយការណ៍សរុបលេខ៖ ៣៣/២០២៣ ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២៣ របស់កងរាជអាវុធហត្ថខេត្តតាកែវ។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ៖ ០០៣ ដ.ស.ព/២៤ ចុះថ្ងៃទី០៣ ខែមករា ឆ្នាំ២០២៤ របស់តំណាងអយ្យការអមសាលាដំបូងខេត្តតាកែវ។

-បានឃើញ ដីកាដំណោះស្រាយលេខ៖ ២១/២០២៤ ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០២៤ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តតាកែវ។

-បានឃើញ ដីកាចាត់តាំងក្រុមប្រឹក្សាជំនុំជម្រះលេខ៖ ៥៤ ដចត/២៤ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០២៤ របស់ប្រធានសាលាដំបូងខេត្តតាកែវ។

-បានឃើញឯកសារផ្សេងៗក្នុងសំណុំរឿងព្រហ្មទណ្ឌខាងលើ។

**អង្គហេតុដែលប្តឹងមកតុលាការមានដូចតទៅ:**

កាលពីថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២៣ វេលាម៉ោង ១៤ និង០០នាទី កម្លាំងមន្ទីរស្រាវជ្រាវ និងបង្ក្រាបបទល្មើសនៃការិយាល័យប្រឆាំងគ្រឿងញៀន នៃកងរាជអាវុធហត្ថខេត្តតាកែវ បានចុះបង្ក្រាបករណីជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀននៅចំណុចភូមិមឿងចារ ឃុំជាងទង និងភូមិណែងស្រាយ ឃុំតាភេម ស្រុកត្រាំកក់ ខេត្តតាកែវ ហើយបានធ្វើការឃាត់ខ្លួនជនត្រូវចោទចំនួន ០៧នាក់រួមមានឈ្មោះ [redacted] វុធ ភេទប្រុស អាយុ៣២ឆ្នាំ, ឈ្មោះ [redacted] ចនតូនី ភេទប្រុស អាយុ២២ឆ្នាំ, ឈ្មោះ [redacted] កក្កដា ភេទប្រុស អាយុ១៧ឆ្នាំ, ឈ្មោះ [redacted] វណ្ណី ភេទប្រុស អាយុ១៨ឆ្នាំ, ឈ្មោះ[redacted] វ៉ាន់ថា ភេទប្រុស អាយុ៣៥ឆ្នាំ, ឈ្មោះ [redacted] គង្គ ភេទប្រុស អាយុ២៩ឆ្នាំ និងឈ្មោះ[redacted] សំណាង ភេទប្រុស អាយុ៣៤ឆ្នាំ ព្រមទាំងបានដកហូតវត្ថុតាងរួមមានម្សៅក្រាមពណ៌សថ្លាចំនួន ០៧ កញ្ចប់ ទម្ងន់ ៤៥. ៥៥ក្រាម (ថ្លឹងទាំងសំបកថង់), ជញ្ជីងថ្លឹងថ្នាំញៀនចំនួន ០១គ្រឿង ទូរស័ព្ទចំនួន ០៧គ្រឿង, ម៉ូតូចំនួន ០២គ្រឿង, ស្លាកលេខឡានចំនួន ០២សន្លឹក, ស្លាកលេខម៉ូតូចំនួន ០១សន្លឹក, ដាវចំនួន ០១ដើម, កាមេរ៉ាសុវត្ថិភាពចំនួន ០១គ្រឿង និងថង់វេចខ្ចប់ថ្នាំញៀន និងសម្ភារៈសេពថ្នាំញៀនមួយចំនួន។ ក្រោយការសាកសួរចំពោះមុខតំណាងអយ្យការជនត្រូវចោទឈ្មោះ [redacted] វុធ បានឆ្លើយសារភាពថា ខ្លួនពិតជាបានទិញថ្នាំញៀនពីឈ្មោះ [redacted] គា ហើយខ្លួនបានយកមកចែកចាយបន្តប្រាកដមែន។ ដោយឡែកជនសង្ស័យឈ្មោះ [redacted] ចនតូនី, ឈ្មោះ [redacted] កក្ក



Scanned with CamScanner

ជា, ឈ្មោះ [redacted] វណ្ណី, ឈ្មោះ [redacted] វ៉ាន់ថា, ឈ្មោះ [redacted] គង្គា និងឈ្មោះ [redacted] សំណាង ជាប់ពាក់ព័ន្ធនឹងការប្រើប្រាស់គ្រឿងញៀន តំណាងអយ្យការសម្រេចបំបែកសំណុំរឿងជាពីរតាមនីតិវិធី។

**នាពេលសវនាការ**

-ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **វុធ ហៅ តុង** បានឆ្លើយថា៖ ចំពោះរឿងហេតុដែលចោទប្រកាន់នេះ គឺនៅថ្ងៃកើតហេតុខ្ញុំបាទពិតជាបានប្រព្រឹត្តពិតមែន។ ដោយកន្លងមកខ្ញុំធ្លាប់ប្រើប្រាស់ថ្នាំញៀនជិតដប់ឆ្នាំបកហើយ និងធ្លាប់លក់ថ្នាំញៀនប្រហែលជា ០៥ ទៅ ០៦បើកមកហើយដែរ ក្រោយមកទៀតខ្ញុំក៏បានឈប់ធ្វើសកម្មភាពនេះហើយដែរ។ ចំពោះថ្នាំញៀនដែលខ្ញុំទិញពីឈ្មោះ **គា** ម្តងៗតម្លៃចាប់ពី ៨០០,០០០ (ប៉ែតសិបម៉ឺន) រៀលទៅ ១,៦០០,០០០ (មួយលានហុកសិបម៉ឺន) រៀល ហើយបានយកមកវែកែកជាកញ្ចប់ដើម្បីយកទៅលក់បន្ត និងក្រោយពេលលក់រួច គឺចំណេញបានប្រាក់ពី ២០ម៉ឺនរៀល ទៅ ៣០ម៉ឺនរៀលប៉ុណ្ណោះ។ ហើយជាក់ស្តែងនៅមុនពេលដែលមានរឿងហេតុនេះ គឺខ្ញុំបាទបានទៅទិញថ្នាំញៀនពីឈ្មោះ គា តម្លៃ ១,៦០០,០០០ (មួយលានហុកសិបម៉ឺន) រៀល បម្រុងនឹងយកមកវែកែកបន្ត តែមិនទាន់បានវែកែកនោះទេ ដោយខ្ញុំកំពុងអង្គុយជក់សិន ក៏មានសមត្ថកិច្ចមកដល់ និងបានឃាត់ខ្លួនខ្ញុំបាទតែម្តង។

-អំណានចម្លើយបំភ្លឺរបស់សាក្សីឈ្មោះ [redacted] **ចនតូនី** បានឆ្លើយថា៖ ចំពោះថ្នាំញៀនដែលពួកខ្លួនជក់ និងថ្នាំញៀនដែលសមត្ថកិច្ចរកឃើញ រួមទាំងជញ្ជីងថ្លឹងថ្នាំញៀននោះ គឺមិនមែនជារបស់ខ្លួនទេ គឺជារបស់បង **តុង** ពីព្រោះកាលពីប្រហែល ៥ថ្ងៃមុនបង **តុង** គាត់បានមកសុំផ្ទះរបស់ខ្លួនស្នាក់នៅ ហើយក្នុងប៉ុន្មានថ្ងៃនេះ គឺខ្លួនមិនបាននៅផ្ទះរបស់ខ្លួនជាប់លាប់ ដោយខ្លួននៅផ្ទះរបស់សង្សារតែខ្លួនបានមកជក់ថ្នាំញៀនជាមួយគាត់នៅផ្ទះរបស់ខ្លួនមួយភ្លែតៗដែរហើយថ្នាំញៀនដែលខ្លួនជក់រាល់លើក គឺជារបស់បង **តុង** ដែរ។ នៅរយៈពេលដែលបង **តុង** មកផ្ទះរបស់ខ្លួនបានឃើញមានគេចូលមកជួបគាត់ និងហុចលុយអោយគាត់ប្រហែលជាទាក់ទងគ្នាទិញថ្នាំញៀនពីគាត់។ ខ្លួនបានស្គាល់បង **តុង** រយៈពេលប្រហែល ១ខែជាង ដោយគាត់ធ្លាប់មកផ្ទះរបស់ខ្លួនបានចំនួនប្រហែល ៧ដង ហើយរាល់ដង គឺគាត់ និងខ្លួនតែងតែជក់ថ្នាំញៀនជាមួយគ្នា។ ក្រៅពីជក់ថ្នាំញៀនជាមួយគាត់ គឺខ្លួនមិនមានទំនាក់ទំនងរកស៊ីថ្នាំញៀនជាមួយគាត់ទេ តែខ្លួនធ្លាប់ទិញថ្នាំញៀនពីគាត់យកមកជក់ចំនួន ២ ទៅ ៣ដង ដោយក្នុង ១ដងតម្លៃ ២ម៉ឺនរៀល ៣ម៉ឺនរៀល។ លើសពីនេះខ្លួនមិនបានដឹងរឿងអ្វីផ្សេងទៀតឡើយ។ ថ្នាំញៀន គឺខ្លួនចេះជក់បានរយៈពេល ៤ខែ។

-អំណានចម្លើយបំភ្លឺរបស់សាក្សីឈ្មោះ [redacted] **វណ្ណី** បានឆ្លើយថា៖ ឈ្មោះ **តុង** បានទូរស័ព្ទមកខ្លួនឱ្យទៅជួបគាត់នៅផ្ទះរបស់ឈ្មោះ តូនី លុះពេលទៅដល់ក៏បានចូលទៅក្នុងផ្ទះប្រហែល ៥នាទីស្រាប់តែសមត្ថកិច្ចចូលមកចាប់ខ្លួន។ កន្លងមកខ្លួនធ្លាប់មកជក់ថ្នាំញៀននៅផ្ទះរបស់ឈ្មោះ តូនី បានចំនួន ២លើក ដោយខ្លួនមកជក់ទាំងពីរលើកនោះ គឺកាលពីថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២៣ និងលើកទី៣ ខ្លួនមិនទាន់បានជក់ផងក៏ត្រូវសមត្ថកិច្ចមកទាន់។ ការជក់ថ្នាំញៀននេះ គឺខ្លួនជក់ដោយសារឈ្មោះ **ទង** ជាអ្នកឱ្យជក់។ ចំពោះការជក់ថ្នាំញៀន គឺចេះជក់រយៈពេល ២ខែ។

-អំណានចម្លើយបំភ្លឺរបស់សាក្សីឈ្មោះ [redacted] **កក្កដា** បានឆ្លើយថា៖ នៅវេលាម៉ោង ៩ និង ៥០នាទីថ្ងៃកើតហេតុខ្លួនបានជិះម៉ូតូជាមួយឈ្មោះ [redacted] វ៉ាន់ឌី ([redacted] វណ្ណី) ទៅផ្ទះឈ្មោះ តូនី ដើម្បីយកស្បែកជើងពេលនោះឈ្មោះ តូនី បានហៅរូបគេជក់ថ្នាំញៀនបានប្រហែល ២ទៅ៣នាទី ក៏ត្រូវសមត្ថ

កិច្ចចាប់ខ្លួនបាន។ រូបខ្លួនចេះប្រើប្រាស់ថ្នាំញៀនរយៈពេល ២ខែមកហើយ ពេលជក់ថ្នាំញៀនម្តងៗ រូបខ្លួនជក់ជាមួយឈ្មោះ តូនី ហើយពេលខ្លះរូបខ្លួនទិញពីឈ្មោះ តូនី ទៅជក់នៅផ្ទះមិត្តភក្តិរបស់ខ្លួន នៅជិតផ្ទះ រាល់ការទិញថ្នាំញៀនម្តងតម្លៃ ២ម៉ឺនរៀល ដើម្បីយកមកជក់។ កន្លងមករូបខ្លួនបានមក ជក់ថ្នាំញៀននៅផ្ទះ តូនី បានចំនួនប្រហែល ១០ដង ហើយថ្នាំញៀននេះ គឺឈ្មោះ តូនី ជាអ្នកទិញ អោយជក់។

-អំណានចម្លើយបំភ្លឺរបស់សាក្សីឈ្មោះ [redacted] **វ៉ាន់ថា** បានឆ្លើយថា៖ នៅម៉ោង ៨ព្រឹកខ្លួនបាន ធ្វើដំណើរមកដល់ផ្ទះ បងគា ក្នុងគោលបំណងមកយកដីទៅដាក់ដំណាំដូង ល្ពៅ នៅក្នុងចំការ ពេល ខ្លួនចូលដល់ក្នុងផ្ទះបានប្រហែលជិតមួយម៉ោងនៅអង្គុយលេងក្នុងកញ្ចុះ ស្រាប់តែខ្លួនបានឃើញ កម្លាំងសមត្ថកិច្ចចូលមកដល់ចាប់ឃាត់ខ្លួន ព្រមទាំងឆែកឆេរក្នុងផ្ទះ ដោយបានរកឃើញវត្ថុតាងមាន ដូចជាម្សៅក្រាមពណ៌សថ្លាមួយកញ្ចប់តូច សម្ភារៈសេពថ្នាំញៀន និងសម្ភារៈវេចខ្ចប់ថ្នាំញៀនមួយ ចំនួន ខ្លួនបានស្គាល់ឈ្មោះ គា តាំងពីខ្លួននៅតូចៗជាមួយគ្នា ព្រោះជាអ្នកភូមិអង្គតាសោម ឃុំអង្គតា សោម ទើបតែមួយរយៈមួយខែក្រោយនេះខ្លួនមានទំនាក់ទំនងចេញចូលក្នុងផ្ទះរបស់ឈ្មោះ គា។ មានពេលខ្លះឈ្មោះ គា បានប្រើខ្លួនអោយបើកឡានជូនទៅស្ទូចត្រី នៅបឹងតាកែវ នៅព្រៃក្តួច និង ពេលខ្លះជួយជូនទៅតាមខេត្តឆ្ងាយៗ។ កន្លងមកខ្លួនធ្លាប់មកជក់ថ្នាំញៀននៅក្នុងកញ្ចុះផ្ទះបង គា បានចំនួន ៣ដង ការជក់ថ្នាំញៀន គឺខ្លួនជក់ជាមួយឈ្មោះ ពៅ និង ឈ្មោះ គា ជួនកាលជក់ជាមួយ មិត្តភក្តិច្រើននាក់ ដែលមកលេងក្នុងផ្ទះបងគា។ ក្រៅពីនេះខ្លួនមិនបានដឹងរឿងអ្វីទៀតទេ។ ចំពោះ ការជក់ថ្នាំញៀន គឺខ្លួនចេះជក់រយៈពេល ១ឆ្នាំជាងហើយ។

-អំណានចម្លើយបំភ្លឺរបស់សាក្សីឈ្មោះ [redacted] **គង្គា** បានឆ្លើយថា៖ មុនពេលសមត្ថកិច្ចចាប់ខ្លួន គឺរូបខ្លួននៅផ្ទះបងគាជួយធ្វើការងារក្នុងផ្ទះបង គា ក្នុងភូមិកើតហេតុតាំងព្រឹករហូតដល់ម៉ោង ប្រហែល ៩ជាងមានបុរសម្នាក់នាក់បានជិះម៉ូតូចូលមកផ្ទះបង គា ហើយជក់ថ្នាំក្នុងកញ្ចុះ ហើយហៅ ខ្លួនជកមេ (ជក់ថ្នាំញៀន) ខ្លួនក៏ដើរមកដាក់មួយដង្ហើមក៏ត្រលប់ទៅក្រោយ វិញអង្គុយលេញបានមួយ សន្ទុះសមត្ថកិច្ចមកដល់ខ្លួនបានរត់បានប្រហែល ១០០ម៉ែត្រ សមត្ថកិច្ចឃាត់ខ្លួនឆែកក្នុងហោប៉ៅ របស់ខ្លួនដកហូតថ្នាំញៀនចំនួន ១កញ្ចប់ ទូរស័ព្ទចំនួន ១គ្រឿង (ចាស់) បន្ទាប់មកបញ្ជូនខ្លួនមកទី បញ្ជាការកងរាជអាវុធហត្ថខេត្តតាកែវ។ ចំពោះថ្នាំញៀនដែលសមត្ថកិច្ចរកឃើញក្នុងហោប៉ៅរបស់ ខ្លួនមិនមែនជារបស់ខ្លួនទេ គឺខ្លួនយកខោគេស្លៀកក្នុងផ្ទះបង គា តែមិនដឹងថាខោរបស់នាក់ណាទេ ខ្លួនបានស្គាល់បង គា រយៈពេលប្រហែល២ខែ ចេញចូលផ្ទះគាត់ និងបានប្រើប្រាស់ថ្នាំញៀននៅផ្ទះ របស់គាត់បានចំនួន ២ដងជាមួយកូនចៅបងគា ថ្នាំញៀនខ្លួនចេះជក់បានរយៈពេល ២ខែហើយ។

-អំណានចម្លើយបំភ្លឺរបស់សាក្សីឈ្មោះ [redacted] **សំណាង ហៅ ពៅ** បានឆ្លើយថា៖ ខ្លួនពីមុនធ្លាប់ បានសមត្ថកិច្ចចាប់ខ្លួនម្តងរួចមកហើយក្នុងករណីប្រើប្រាស់គ្រឿងញៀន។ មុនសមត្ថកិច្ចចាប់ខ្លួន គឺ ខ្លួននៅផ្ទះឈ្មោះ គា តាំងពីព្រឹកលុះដល់ម៉ោងកើតហេតុស្រាប់តែខ្លួនបានឃើញកម្លាំងសមត្ថកិច្ច ចូលមកដល់ចាប់ឃាត់ខ្លួននៅផ្ទះឈ្មោះ គា នៅភូមិណាងស្រាយ ឃុំតាភេម ស្រុកត្រាំកក់ ហើយ សមត្ថកិច្ចបានឆែកឆេររកឃើញវត្ថុតាងមួយចំនួនមានសំភារៈសេព និងថង់វេចខ្ចប់ថ្នាំញៀន។ កន្លង មកខ្លួនរស់នៅផ្ទះរបស់ឈ្មោះ គា នេះ ពេលឈ្មោះ គា យកថ្នាំញៀន គឺខ្លួនយកមកច្រកវេចខ្ចប់ជា

កញ្ចប់តូចៗ ឬធំតាមដែលគេកម្ម៉ង់ទិញដូចជាកញ្ចប់តូចខ្លួនលក់មួយកញ្ចប់ក្នុងតម្លៃ ២ម៉ឺនរៀល ទៅ ៣០ម៉ឺនរៀល និងពីមុនខ្លួនធ្លាប់ទិញថ្នាំញៀនពីឈ្មោះ គា បានចំនួន ២ដង ដោយក្នុង ១ដង ខ្លួនទិញក្នុងតម្លៃ ៣០ម៉ឺនរៀល។ ក្នុងការទំនាក់ទំនងឈ្មោះ គា ខ្លួនបានស្គាល់គាត់រយៈពេល ១០ឆ្នាំជាងហើយ តែទើបមួយរយៈចុងក្រោយនេះខ្លួនមានទំនាក់ទំនងជាមួយឈ្មោះ គា ហើយមកនៅមើលដី និងមើលថែផ្ទះអោយឈ្មោះ គា។ ហើយរយៈពេលកន្លងមកខ្លួនធ្លាប់យកថ្នាំញៀនទៅលក់ឱ្យគេនៅម្តុំជិតផ្ទះឈ្មោះ គា បានប្រហែល ៥លើក ដោយលក់ក្នុងតម្ល ២ម៉ឺនរៀល ទៅ ៣ម៉ឺនរៀល តែរយៈពេល ១ខែនេះឈ្មោះ គា លែងប្រគល់ការងារអោយខ្លួនទ គឺនៅចាំតែមើលផ្លូវមុខ ក្រោយខ្លាចមានសមត្ថកិច្ចចូលមកដល់។ រាល់ថ្ងៃឈ្មោះ គា បានទុកថ្នាំញៀនចំនួន ១កញ្ចប់ក្នុងតម្លៃ ៤ម៉ឺនរៀលសំរាប់ខ្លួនជាមួយអ្នករស់នៅជាមួយឈ្មោះ គា ដូចជាឈ្មោះ វ៉ាន់ថា។ ចំពោះការប្រើប្រាស់ថ្នាំ ញៀនគឺខ្លួនចេះជក់រយៈពេល ៥ខែហើយ។

-ជនជាប់ចោទឈ្មោះ [redacted] **វុធ ហៅ តុង** បានធ្វើសេចក្តីកត់សម្គាល់ខ្លីៗថា៖ ខ្ញុំបាទធ្លាប់លក់ថ្នាំញៀនត្រឹមតែ ១សប្តាហ៍ទៅ ១០ថ្ងៃទើបខ្លួនលក់ថ្នាំញៀនអស់ ខ្ញុំចេះលក់ដូរថ្នាំញៀនបាន៥ខែមកហើយ។

-តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា៖ ក្រោយពីបានសួរដេញដោល និងស្តាប់ចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ [redacted] **វុធ ហៅ តុង** ព្រមទាំងភស្តុតាងនានាដែលមានក្នុងសំណុំរឿង គឺតំណាងអយ្យការនៅតែតម្កល់ការចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរទុកជាបានការដដែល ដោយសុំឱ្យផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] **វុធ ហៅ តុង** ពីបទ៖ **ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** និងឈ្មោះ [redacted] **គា** ពីបទ៖ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ដដែល និងសុំដល់ក្រុមប្រឹក្សាសម្រេចតាមកំណត់ច្បាប់។

-លោក [redacted] មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានការពារកូនក្តីខ្លួនថា៖ ឆ្លងតាមការសួរដេញដោលនៅក្នុងអង្គសវនាការនេះឃើញថាកូនក្តីខ្ញុំឈ្មោះ [redacted] **វុធ ហៅ តុង** បានឆ្លើយសារភាពថា៖ ចំពោះរឿងហេតុនេះ គឺខ្លួនពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់ពិតមែន ហើយគ្រឿងញៀនដែលខ្លួនយកមកវេចខ្ចប់ និងយកមកប្រើប្រាស់នោះ គឺបានទិញពីឈ្មោះ **គា** ក្នុងតម្លៃចន្លោះពី ៨០ម៉ឺនរៀល ទៅ ១លាន ៦០ម៉ឺនរៀល។ ហើយឃើញថាកូនក្តីខ្ញុំបាទបានឆ្លើយនៅពេលនេះ គឺបានសារភាពគ្រប់បែបយ៉ាង និងពុំបង្កការស្មុគស្មាញដល់តុលាការនោះទេ។ ហេតុដូច្នេះក្នុងនាមខ្ញុំបាទជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ គឺសូមស្នើសុំដល់តុលាការសម្រេចពិចារណាក្នុងការផ្តន្ទាទោសលើកូនក្តីខ្ញុំបាទ និងមេត្តាបន្ធូរបន្ថយទោសដល់កូនក្តីខ្ញុំបាទផង។

-លោក [redacted] មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានការពារកូនក្តីខ្លួនថាឃើញថានៅក្នុងអង្គសវនាការនេះកូនក្តីខ្ញុំបាទបានឆ្លើយសារភាពនូវកំហុសរបស់ខ្លួនហើយ ដោយគាត់មានការភ្ញាក់រឭក និងសហការក្នុងការផ្តល់ចម្លើយជូនតុលាការទៀតផង។ ហេតុនេះក្នុងនាមខ្ញុំបាទជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទសូមស្នើសុំដល់តុលាការមេត្តាសម្រេចបន្ធូរបន្ថយទោសដល់កូនក្តីខ្ញុំបាទផង។



Scanned with CamScanner

-សម្ដីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] វុធ ហៅ តុង ថា៖ ខ្ញុំបាទសំណូមពរដល់តុលាការមេត្តាបន្ធូរបន្ថយទោស និងសម្រាលទោសដល់រូបខ្ញុំផង ព្រោះខ្ញុំបានដឹងពីកំហុសហើយ និងសន្យាថាពេលចេញពីពន្ធនាគារវិញឈប់ប្រព្រឹត្តអំពើទាំងនេះទៀតហើយ។

-**ក្រោយពីបាន** ស្ដាប់ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **វុធ ហៅ តុង**។

-**ក្រោយពីបាន** ស្ដាប់អំណានចម្លើយបំភ្លឺរបស់សាក្សី។

-**ក្រោយពីបាន** ពិនិត្យឯកសារ និងភស្តុតាងពាក់ព័ន្ធក្នុងសំណុំរឿង។

-**ក្រោយពីបាន** ស្ដាប់សេចក្តីកត់សម្គាល់ខ្លីៗរបស់ជនជាប់ចោទ។

-**ក្រោយពីបាន** ស្ដាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ ។

-**ក្រោយពីបាន** ស្ដាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ។

-**ក្រោយពីបាន** ស្ដាប់សំណូមពរចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] **វុធ ហៅ តុង**។

-**ក្រោយពីបាន** ពិភាក្សាសម្ងាត់ជាមួយនឹងក្រុមប្រឹក្សាជំនុំជម្រះរួចហើយ។

-**ក្រោយពីបាន** ពិចារណាត្រឹមត្រូវតាមច្បាប់រួចរាល់ហើយ ។

## សំអាងហេតុ

១-ក្រោយពីធ្វើការស៊ើបសួរតាមនីតិវិធីចប់សព្វគ្រប់ហើយ ចៅក្រមស៊ើបសួរបានចេញដីកាដំណោះស្រាយលេខ៖ ២១/២០២៤ ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០២៤ ដោយបានសម្រេចបញ្ជូនជនត្រូវចោទឈ្មោះ [redacted] **វុធ ហៅ តុង** មកជំនុំជម្រះពីបទ៖ **ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** បទល្មើសដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងឈ្មោះ [redacted] **គា** មកជំនុំជម្រះពីបទ៖ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** បទល្មើសដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២-តាមចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ [redacted] **វុធ ហៅ តុង** និងអំណានចម្លើយបំភ្លឺរបស់សាក្សី ព្រមទាំងរបាយការណ៍នានារបស់កងរាជអាវុធហត្ថខេត្តតាកែវ បញ្ជាក់ឱ្យឃើញថា៖ កាលពីថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២៣ ស្ថិតនៅចំណុចភូមិមឿងចារ ឃុំជាងទង និងភូមិណាងស្រាយ ឃុំតាភេម ស្រុកត្រាំកក់ ខេត្តតាកែវ ពិតជាមានករណីជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន និងករណីជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ដែលបង្កឡើងដោយជនជាប់ចោទឈ្មោះ [redacted] **គា** ពិតប្រាកដមែន។ ក្រោយមកសមត្ថកិច្ចបានកសាងសំណុំរឿងបញ្ជូនមកតុលាការដើម្បីចាត់ការតាមនីតិវិធីច្បាប់តែម្តង។

៣-ផ្អែកតាមកំណត់ហេតុធ្វើតេស្តពិសោធន៍រកសារធាតុញៀនក្នុងខ្លួនលេខ៖ ២៩/២០២៣ ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២៣ របស់កងរាជអាវុធហត្ថខេត្តតាកែវ ឃើញថា: ជនជាប់ចោទឈ្មោះ [redacted] **វុធ ហៅ តុង** ពិតជាមានផ្ទុកនូវសារធាតុញៀននៅក្នុងខ្លួនរបស់គេពិតមែន។

៤-ផ្អែកតាមលទ្ធផលកោសលវិច័យគ្រឿងញៀនលេខ៖៤៤៥៧៣/២៣ ម.ព.អ.ជ.ប.គ.ញ ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២៣ របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនបញ្ជាក់ឃើញថា: ម្សៅក្រាមសថ្លាចំនួន ០៧កញ្ចប់មានទម្ងន់ ៤១.៤៣ (សែសិបមួយក្បៀសសែសិបបី) ក្រាម (ថ្លឹងថ្នាំសុទ្ធ)



Scanned with CamScanner

ដែលជារបស់ជនជាប់ចោទឈ្មោះ [redacted] វុធ ហៅ តុង មានវិជ្ជមានសារធាតុញៀនប្រភេទមេតំហ្វេតាមីនដែលមានបរិមាណសារធាតុមេតំហ្វេតាមីនគិតជាភាគរយនៃទម្ងន់ ៧៧.១៩% នាំឱ្យមានបរិមាណធាតុសុទ្ធស្មើនឹង ៣១.៩៧ (សាមសិបមួយក្រៀសកៅសិបប្រាំពីរ) ក្រាម។

៥-យល់ឃើញថា៖ អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] វុធ ហៅ តុង ដែលបានធ្វើសកម្មភាពទិញថ្នាំញៀនពីឈ្មោះ [redacted] គា ចំនួន ០៧ កញ្ចប់មានទម្ងន់ ៤១.៤៣ (សែសិបមួយក្រៀសសែសិបបី) ក្រាម (ថ្លឹងថ្នាំសុទ្ធ) ដើម្បីយកទៅប្រើប្រាស់ និងរំលែកលក់បន្ត ដោយចេតនាទុច្ចរិត គឺជាអំពើដែលធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ និងសន្តិសុខសង្គម ជាពិសេសធ្វើឱ្យប៉ះពាល់ដល់សុខភាពរបស់ខ្លួនឯង និងសុខភាពរបស់អ្នកដទៃទៀតផង ហើយអំពើនោះទៀតសោតត្រូវបានច្បាប់ហាមឃាត់ និងកំណត់ថាជាបទ៖ **ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** បទល្មើសដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌទី៣ និងទី៥ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៦-យល់ឃើញថា៖ អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] គា ដែលបានធ្វើសកម្មភាពចែកចាយនូវថ្នាំញៀនចំនួន ០៧ កញ្ចប់ មានទម្ងន់ ៤១.៤៣ (សែសិបមួយក្រៀសសែសិបបី) ក្រាម (ថ្លឹងថ្នាំសុទ្ធ) ឱ្យទៅឈ្មោះ [redacted] វុធ ហៅ តុង ដើម្បីយកទៅប្រើប្រាស់ និងចែកចាយបន្តដោយចេតនាទុច្ចរិត គឺជាអំពើដែលធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ និងសន្តិសុខសង្គម ជាពិសេសធ្វើឱ្យប៉ះពាល់ដល់សុខភាពរបស់អ្នកដទៃទៀតផង ហើយអំពើនោះទៀតសោតត្រូវបានច្បាប់ហាមឃាត់ និងកំណត់ថាជាបទ៖ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** បទល្មើសដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌទី៣ និងទី៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៧-យល់ឃើញថា៖ ជនជាប់ចោទឈ្មោះ [redacted] វុធ ហៅ តុង ភេទប្រុស អាយុ៣២ឆ្នាំ និងឈ្មោះ [redacted] គា ភេទប្រុស អាយុ៣៥ឆ្នាំ (កើតថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ១៩៨៨) គឺជានីតិជនដែលមានស្មារតីយល់ដឹង និងមានសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌដែលកើតចេញពីអំពើដែលខ្លួនបានប្រព្រឹត្ត។

៨-យល់ឃើញថា៖ មានធាតុផ្សំបទល្មើសគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] វុធ ហៅ តុង ភេទប្រុស អាយុ៣២ឆ្នាំ ពីបទ៖ **ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិមឿងចារ ឃុំជាងទង និងភូមិណាងស្រាយ ឃុំតាភេម ស្រុកត្រាំកក់ ខេត្តតាកែវ កាលពីថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២៣ បទល្មើសដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌទី៣ និងទី៥ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៩-យល់ឃើញថា៖ មានធាតុផ្សំបទល្មើសគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] គា ភេទប្រុស អាយុ៣៥ឆ្នាំ (កើតថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ១៩៨៨) ពីបទ៖ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិមឿងចារ ឃុំជាងទង និងភូមិណាងស្រាយ ឃុំតាភេម ស្រុកត្រាំកក់ ខេត្តតាកែវ កាលពីថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២៣ បទល្មើសដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌទី៣ និងទី៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។



Scanned with CamScanner

១០-យល់ឃើញថា៖ ចំពោះថ្នាំញៀនដែលសមត្ថកិច្ចបានដកហូតពីជនជាប់ចោទឈ្មោះ [redacted] **វុធ ហៅ តុង** ដែលជននេះបានទិញពីឈ្មោះ [redacted] **គា** មានចំនួន ០៧ កញ្ចប់ មានទម្ងន់ ៤១.៤៣ (សែសិបមួយក្បៀសសែសិបបី) ក្រាម (ថ្លឹងថ្នាំសុទ្ធ) មានបរិមាណធាតុសុទ្ធសរុបស្មើនឹង ៣១.៩៧ (សាមសិបមួយក្បៀសកៅសិបប្រាំពីរ) ក្រាម នាំឱ្យបទល្មើសដែលត្រូវផ្តន្ទាទោសគឺជាបទ៖ **ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** បទល្មើសដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌទី៣ និងកថាខណ្ឌទី៥ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

១១-តាមការប្តឹងសុំរបស់តំណាងអយ្យការដោយសុំឱ្យតុលាការផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] **វុធ ហៅ តុង** ពីបទ៖ **ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** និងឈ្មោះ [redacted] **គា** ពីបទ៖ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន**។ តុលាការយល់ឃើញថាការប្តឹងសុំនេះមានមូលដ្ឋានតាមផ្លូវច្បាប់គ្រប់គ្រាន់ គប្បីសម្រេចតាមការប្តឹងសុំ។

១២-តាមសេចក្តីសន្និដ្ឋានសុំរបស់លោក [redacted] និងលោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] **វុធ ហៅ តុង** ដោយសំណូមពរដល់ក្រុមប្រឹក្សាជំនុំជម្រះបន្ធូរបន្ថយទោសដល់កូនក្តីខ្លួនដោយសំអាងថាកូនក្តីខ្លួនមានការភ្ញាក់រឭ ឆ្លើយសារភាពចំពោះតុលាការ និងមានការសោកស្តាយចំពោះអំពើដែលខ្លួនបានប្រព្រឹត្តផងដែរ។ តុលាការយល់ឃើញថា៖ ការស្នើសុំនេះមានមូលដ្ឋាន និងមានហេតុផលសមរម្យ។ ហេតុនេះគប្បីតុលាការសម្រេចពិចារណាសម្រេចតាមច្បាប់។

១៣-យល់ឃើញថា៖ នាពេលសវនាការជំនុំជម្រះជនជាប់ចោទឈ្មោះ [redacted] **វុធ ហៅ តុង** មានការភ្ញាក់រឭក និងដឹងកំហុសនូវអំពើដែលខ្លួនបានប្រព្រឹត្ត ក៏ប៉ុន្តែឃើញថាទំហំនៃការប្រព្រឹត្តរបស់ជននេះកន្លងមកក៏មានសកម្មភាពធំដុំផងដែរ។ ហេតុដូច្នេះគប្បីតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារលើជនជាប់ចោទឈ្មោះ [redacted] **វុធ ហៅ តុង** កំណត់ចំនួន **០៦ (ប្រាំមួយ) ឆ្នាំ** និងពិន័យជាប្រាក់ចំនួន **១០.០០០.០០០ (ដប់លាន) រៀល**។

១៤-យល់ឃើញថា៖ ចំពោះសកម្មភាពរបស់ជនជាប់ចោទឈ្មោះ [redacted] **គា** គឺជាមេខ្លោងដែលបានធ្វើការចែកចាយនូវថ្នាំញៀនយ៉ាងសកម្មភាពនៅក្នុងមូលដ្ឋានឱ្យទៅអ្នកដទៃដើម្បីយកទៅប្រើប្រាស់ ដែលធ្វើឱ្យប៉ះពាល់ដល់សង្គមយ៉ាងធ្ងន់ធ្ងរ។ ហេតុដូច្នេះគប្បីតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធ នាគារលើជនជាប់ចោទឈ្មោះ [redacted] **គា** កំណត់ចំនួន **០៧ (ប្រាំពីរ) ឆ្នាំ** និងពិន័យជាប្រាក់ចំនួន **១០.០០០.០០០ (ដប់លាន) រៀល**។

១៥-យល់ឃើញថា៖ ចៅក្រមស៊ើបសួរបានចេញដីកាបង្គាប់ឱ្យចាប់ខ្លួនលេខ៖ ២៧៧/២៣ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣ លើជនជាប់ចោទឈ្មោះ [redacted] **គា** ភេទប្រុស អាយុ៣៥ឆ្នាំ (កើតថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ១៩៨៨) ហើយជននាក់នេះត្រូវបានតុលាការសម្រេចផ្តន្ទាទោសតាមអំណាចសាលក្រមខាងលើនេះហើយ។ហេតុដូច្នេះគប្បីតុលាការសម្រេចចេញដីកាបញ្ឈប់អានុភាពដីកាបង្គាប់ឱ្យចាប់ខ្លួនរបស់ចៅក្រមស៊ើបសួរ។



Scanned with CamScanner

១៦-យល់ឃើញថា៖ ជនជាប់ចោទឈ្មោះ [redacted] គា ភេទប្រុស អាយុ៣៥ឆ្នាំ (កើតថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ១៩៨៨) ត្រូវបានតុលាការរកឃើញថាមានពិរុទ្ធភាពពីបទ៖ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** បទល្មើសដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌទី៣ និងទី៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ហើយត្រូវបានតុលាការសម្រេច ផ្តន្ទាទោសដាក់ពន្ធនាគារលើសពី ០១ (មួយ) ឆ្នាំដោយគ្មានការព្យួរ។ មួយវិញទៀតដើម្បីធានាឱ្យជនជាប់ចោទខាងលើនេះ អនុវត្តទោសតាមអំណាចសាលក្រមនេះ ក៏ដូចជាដើម្បីរក្សាសណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ និងសន្តិសុខសង្គមឱ្យបានល្អគប្បីតុលាការចេញដីកាបង្គាប់ឱ្យចាប់ខ្លួនលើជនជាប់ចោទខាងលើនេះ តាមបញ្ញត្តិមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

១៧-យល់ឃើញថា៖ វត្ថុតាងរួមមានក្រាមពណ៌សថ្លាចំនួន ០៧កញ្ចប់មានទម្ងន់ ៤៤.៤៨ក្រាម (ថ្លឹងទាំងសំបកថង់), ជញ្ជីងថ្លឹងថ្នាំញៀនចំនួន ០១គ្រឿង, ថង់វេចខ្ចប់ថ្នាំញៀន និងសម្ភារៈសេពថ្នាំញៀនមួយចំនួន និងដាវដែកចំនួន ០១ដើម ជាវត្ថុតាងដែលជាប់ពាក់ព័ន្ធនឹងបទល្មើសខាងលើ គប្បីតុលាការសម្រេចរឹបអូសតាមបញ្ញត្តិមាត្រា ៩៣ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងមាត្រា ៦២ នៃក្រមព្រហ្មទណ្ឌ។

## ហេតុដូច្នេះសម្រេច

១-ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] វុធ ហៅ តុង ភេទប្រុស អាយុ៣២ឆ្នាំ (អត្តសញ្ញាណខាងលើ) ដាក់ពន្ធនាគារកំណត់ចំនួន **០៦ (ប្រាំមួយ) ឆ្នាំ** និងពិន័យជាប្រាក់កំណត់ចំនួន **១០.០០០.០០០ (ដប់លាន) រៀល** ពីបទ៖ **ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិមឿងចារ ឃុំជាងទង និងភូមិណាងស្រោយ ឃុំតាភេម ស្រុកត្រាំកក់ ខេត្តតាកែវ កាលពីថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២៣ បទល្មើសដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌទី៣ និងទី៥ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២-ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] គា ភេទប្រុស អាយុ៣៥ឆ្នាំ (កើតថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ១៩៨៨) (អត្តសញ្ញាណខាងលើ) ដាក់ពន្ធនាគារកំណត់ចំនួន **០៧ (ប្រាំពីរ) ឆ្នាំ** និងពិន័យជាប្រាក់កំណត់ចំនួន **១០.០០០.០០០ (ដប់លាន) រៀល** ពីបទ៖ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិមឿងចារ ឃុំជាងទង និងភូមិណាងស្រោយ ឃុំតាភេម ស្រុកត្រាំកក់ ខេត្តតាកែវ កាលពីថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២៣ បទល្មើសដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌទី៣ និងទី៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៣-បញ្ចប់អានុភាពនៃដីកាបង្គាប់ឱ្យចាប់ខ្លួនរបស់ចៅក្រមស៊ើបសួរលេខ៖ ២៧៧/២៣ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣ លើជនជាប់ចោទឈ្មោះ [redacted] គា ភេទប្រុស អាយុ៣៥ឆ្នាំ (កើតថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ១៩៨៨)។

៤-ចេញដីកាបង្គាប់ឱ្យចាប់ខ្លួនលើជនជាប់ចោទឈ្មោះ [redacted] គា ភេទប្រុស អាយុ៣៥ឆ្នាំ (កើតថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ១៩៨៨) តាមបញ្ញត្តិមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៥-វត្ថុតាងរួមមានក្រាមពណ៌សថ្លាចំនួន ០៧កញ្ចប់មានទម្ងន់ ៤៤.៤៨ក្រាម (ថ្លឹងទាំងសំបកថង់), ជញ្ជីងថ្លឹងថ្នាំញៀនចំនួន ០១គ្រឿង, ថង់វេចខ្ចប់ថ្នាំញៀន និងសម្ភារៈសេពថ្នាំញៀនមួយចំនួន និងដាវដែកចំនួន ០១ដើម សម្រេចរឹបអូស។



Scanned with CamScanner

-សាលក្រមនេះជំនុំជម្រះជាសាធារណៈនាថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៤ និងប្រកាសជាសាធារណៈនៅថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៤ នៅសាលាដំបូងខេត្តតាកែវ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] **វុធ ហៅ ទង** និងកំបាំងមុខជនជាប់ចោទឈ្មោះ [redacted] **តា**។

-ទុកសិទ្ធិឱ្យប្ដឹងទាស់ និងប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់៕

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមប្រឹក្សា** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សា** |
|---|---|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |

[redacted]

(បានថតចម្លងត្រឹមត្រូវតាមលិខិតដើម)
ថ្ងៃពុធ ២កើត ខែចេត្រ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
តាកែវ,ថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៤
**ក្រឡាបញ្ជីសវនាការ**
[redacted]

បានឃើញ
តាកែវ,ថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៤
**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**
[redacted]



Scanned with CamScanner